**សកម្មភាព** ៖ **ល្បែងសំរាមរត់រកធុង**

**ចិត្តចលភាព** ៖ បំណិនចលនាធំ៖ ការហ្វឹកហាត់បង្កើតកម្លាំងនិងសម្របសម្រួលរវាងចលនាសាច់ដុំតូច និងសាច់ដុំធំ

**វិទ្យាសាស្ត្រ** ៖ បំណិនអនាម័យ៖ ទម្លាប់រស់នៅមានអនាម័យក្នុងគ្រួសារនិងសង្គម

**សិក្សាសង្គម** ៖ បំណិនក្នុងសង្គម៖ ការយល់ដឹងអំពីបរិស្ថានធម្មជាតិនិងវិធីការពារ

**បុរេគណិត** ៖ បរិមាណនិងចំនួន៖ ស្គាល់នឹងយល់លេខតាងនិងការគណនាលេខសាមញ្ញ៖

ទំហំនិងពណ៌៖ ចំណាត់ថ្នាក់ក្រុមនិងលំដាប់លំដោយ៖

**ភាសាខ្មែរ** ៖ ការប្រើពាក្យតាមវេយ្យាករណ៍៖ ការយល់ពីវាក្យស័ព្ទ ឃ្លា និងល្បះ៖

**គោលបំណង**

**ចិត្តចលភាព** ៖ វិជ្ជាសម្បទា៖ ប្រាប់ពីរបៀបវិធីដើរ រត់ លូន វារ លោត ចុះនិងឡើង បោះ តោង ឡើង គប់ ប្រមៀល រុញ និងទាញ ទៅតាមគោលដៅនិងចម្ងាយដែលបានកំណត់។

**វិទ្យាសាស្ត្រ** ៖ បំណិនសម្បទា៖ ចោលសំរាមនៅក្នុងធុងសំរាមឱ្យបានត្រឹមត្រូវ

**សិក្សាសង្គម** ៖ បំណិនសម្បទា៖ ជួយសម្អាតបរិស្ថាន ដូចជាការបោសសំរាម និងមិនបន្ទោរបង់ផ្តេសផ្តាសជាដើម។

**បុរេគណិត** ៖ បំណិនសម្បទា៖ រាប់ចំនួនលេខ និងយល់ន័យពី១ដល់៣០ឬលើសពីនេះ។ បំណិនសម្បទា៖ រៀបវត្ថុតាមលំដាប់ក្រុម ប្រភេទ ទំហំ និងពណ៌។

**ភាសាខ្មែរ** ៖ វិជ្ជាសម្បទា៖ ប្រាប់ពីពាក្យ ឃ្លា ឬល្បះ ឱ្យបានត្រឹមត្រូវទៅតាមស្ថានភាព មនុស្សធំដែលមានចំនួនពី៥ទៅ៦ព្យាង្គឬលើសពីនេះ។

**កម្រិតសិក្សា** ៖ទាប មធ្យមនិង ខ្ពស់

**រយៈពេល** ៖ ៣០ នាទី

**ឧបករណ៍** ៖ កាតធុងសំរាមដែលមាន៤ឬ៥ ដែលមានពណ៌សម្គាល់ដែរ។ (ប្រភេទសំរាមមាន៖១. ពណ៌ស្វាយសំណល់ក្រដាស ២. ពណ៌ខៀវសំណល់កំប៉ុង ៣.ពណ៌បៃតងសំណល់ផ្ទះបាយ ៤. ពណ៌លឿងសំណល់ប្លាស្ទីក និង ៥. ពណ៌ក្រហមសំណល់គ្រោះថ្នាក់ ) ជាទំហំA4 (ពណ៌ / សខ្មៅ)

**ការរៀបចំ** ៖ ត្រៀមសម្ភារ ដូចជាកាតធុងសំរាម ទាំង៥ប្រភេទនេះឱ្យបានរួចរាល់ គឺការស្រេច។

**សេចក្ដីណែនាំ ៖**

1. គ្រូសួរកុមារ តើកូនៗស្គាល់សំរាមដែរឬទេ? សំរាមមានប៉ុន្មានប្រភេទ? អាចឱ្យកុមាររៀបរាប់ប្រាប់ខ្លះៗពីសំរាម។
2. ប្រាប់កុមារថាថ្ងៃនេះយើងនឹងលេងល្បែងសកម្មភាពមួយនៅក្នុងថ្នាក់របស់យើង (ប្រសិនបើក្នុងថ្នាក់តូច មិនមានទីធ្លាលេងទេ អាចលេងក្រៅថ្នាក់ក៏បានដែរ)
3. គ្រូប្រាប់ពីរបៀបលេងល្បែងសកម្មភាពនេះទៅកាន់កុមារជាមុនសិន៖
   - ❖ យកក្រដាសកាតធុងសំរាមទាំង៥ប្រភេទមក និងប្រាប់កុមារពីធុងសំរាមនីមួយៗថាខុសគ្នាបែបណាខ្លះ ហើយសំរាមណាត្រូវដាក់នៅធុងសំរាមណាឱ្យច្បាស់ជាមុនសិន។
   - ❖ ត្រូវលើកឧទាហរណ៍ថា៖ សំរាម ថង់ ដាក់នៅធុងសំរាមមួយណា? គឺ សំណល់ប្លាស្ទីក។ សំរាម ក្រដាសកេស ដាក់នៅធុងសំរាមណា? គឺសំណល់ក្រដាស…។
   - ❖ បង្ហាញនិងប្រាប់កុមារឱ្យបានច្បាស់ពីធុងសំរាម និងប្រភេទសំរាមឱ្យបានច្បាស់សិន។
   - ❖ ឱ្យកុមារ៥នាក់ ទៅឈរនៅ៥កន្លែងផ្សេងៗពីគ្នា ដែលមានគម្លាតឆ្ងាយៗពីគ្នា ដែលតំណាងឱ្យប្រភេទធុងសំរាមទាំង៥ប្រភេទ ហើយកុមារដែលនៅសល់ ត្រូវឈរនៅកណ្ដាល បន្ទាប់មក គ្រូចែកក្រដាសកាតធុងសំរាមដែលបានត្រៀមរួចរាល់ឱ្យទៅកាន់កុមារទាំង៥នោះ ម្នាក់១ផងដែរ បន្ទាប់មក ត្រូវប្រាប់កុមារដែលនៅកណ្ដាលថាកុមារទាំង៥នាក់នោះ មួយណាជាប្រភេទធុងសំរាមណាឱ្យច្បាស់ (បើមិនច្បាស់ទេ ឱ្យកុមារមើលពណ៌ធុងសំរាមបានដូចគ្នាដែរ ព្រោះធុងសំរាមនីមួយៗមានពណ៌សម្គាល់ដែរ)។
   - ❖ គ្រូចាប់ផ្ដើមស្រែក ប្រភេទសំរាមមួយប្រភេទ បន្ទាប់មក ពួកគេទាំងអស់ដែលឈរនៅកណ្ដាលនោះ ត្រូវរត់ទៅរកធុងសំរាមនោះភ្លាមតែម្ដង។ ឧ. គ្រូស្រែកថា ទុយោរ (តើទុយោរជាសំរាមប្រភេទមួយណា? គឺធុងសំណល់ប្លាស្ទីក) ដូច្នេះពួកគេត្រូវរត់ទៅរកកុមារដែលកាន់ក្រដាសកាតធុងសំរាម ប្លាស្ទីក។ បើគ្រូស្រែកថា ថ្មពិល កុមារទាំងអស់ត្រូវរត់ទៅរកកុមារដែលកាន់ក្រដាសកាតធុងសំរាម សំណល់គ្រោះថ្នាក់។
   - ❖ គ្រូអាចឱ្យកុមារម្នាក់ទៀតមកជួយស្រែកពីសំរាមជំនួសគាត់ក៏បានដែរ ដើម្បីឱ្យកុមារបានស្គាល់សំរាមកាន់តែច្បាស់។

❖ ល្បែងនេះ យើងអាចលេងបែបប្រកួតប្រណាំងគ្នាក៏បានដែរ។ កុមារណាដែលរត់ទៅដល់ក្រោយគេ ពួកគេនឹងអាចទៅប្ដូរជាមួយកុមារដែលកាន់ក្រដាសកាតធុងសំរាមវិញបាន។ បើ១នាក់ ដូរ១នាក់ បើ២នាក់ដូរ២នាក់។ ធ្វើបែបនេះអាចឱ្យកុមារទាំងអស់បានលេងទាំងអស់គ្នា និងមិនបានច្រណែនគ្នាជាដើមផងដែរ។

4. បញ្ជាក់៖ គ្រូអាចច្នៃល្បែងនេះទៅជារបៀបលេងផ្សេងទៀតក៏បានដែរ តាមគំនិតរបស់គ្រូ ព្រោះនេះគ្រាន់តែជាគំរូមួយប្រភេទតែប៉ុណ្ណោះ។